# ទំព័រវិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានមោទនភាពនឹងផ្តល់ជូននូវឧបករណ៍ដែល ឪពុកម្តាយ និង ក្រុមគ្រួសារ អាចប្រើ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ កូន និង សាលា របស់ពួកគាត់។

ទំព័រវិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ផ្តល់ឲ្យលោកអ្នកចូលមើល ព័ត៌មានដ៏មានតម្លៃ អំពី ការអប់រំ និង សាលា របស់កូនលោកអ្នក។

មើលព័ត៌មានរបស់កូនលោកអ្នក តាមរយៈទំព័រវិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ៖

- ប្រវត្តិនៃការសិក្សា
- លទ្ធផលនៃការប្រឡង
- វត្តមានអវត្តមាន
- និង អ្វីៗជាច្រើនទៀត!




លោកអ្នកអាចចូលមើលនៅពេលណាក៏បាន តាម កុំព្យូទ័រ កុំព្យូទ័របន្ទះ (តាប្លិត) ឬ ទូរស័ព្ទដៃ

## ទទួលដំណឹងតាម

- សារតាមទូរស័ព្ទដៃ
- ទូរស័ព្ទ
- អ៊ីមែល

លោកអ្នកអាចទទួលដំណឹងអំពីបញ្ហាសំខាន់ៗ ដែលអាចប៉ះពាល់ដល់កូនរបស់លោកអ្នក (ឧ. ការបិទសាលាដែលទាក់ទងនឹងអាកាសធាតុមិនល្អ ដំណឹងអំពីអវត្តមាន និងកម្មវិធីដែលនឹងកើតមានឡើងដែលក្រុមគ្រួសារមានចំណាប់អារម្មណ៍)។

**តើខ្ញុំអាចចុះឈ្មោះសម្រាប់ទំព័រវិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ ថ្មី និងបង្កើតគណនីរបស់ខ្ញុំ ដោយវិធីណា?**

លោកអ្នកត្រូវមានអ៊ីមែលផ្ទាល់ខ្លួនដើម្បីបង្កើតគណនីនៃទំព័រវិបសែសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ។ លោកអ្នកអាចបង្កើតគណនីអ៊ីមែលដោយឥតគិតថ្លៃ ដោយប្រើ ជីមែល (Gmail) អោតលុក (Outlook) យ៉ាហូ (Yahoo) ឬការបម្រើដែលស្រដៀងគ្នានេះ។

ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីវិធីរៀបចំ ទំព័រវិបសែសម្រាប់ មាតាបិតា របស់លោកអ្នក សូមមើលទំព័រម្ខាងទៀត!

THE SCHOOL DISTRICT OF PHILADELPHIA

# ទំព័រវិបសៃសម្រាប់ មាតាបិតា និង ក្រុមគ្រួសារ

## ១) តើខ្ញុំចាប់ផ្តើមពីកន្លែងណា?

គ្រាន់តែចូលទៅ http://signup.philasd.org នៅក្នុងកម្មវិធីវិបសៃរបស់លោកអ្នក ហើយសូមត្រៀម លេខសម្ងាត់សម្រាប់បញ្ជាក់ របស់លោកអ្នក។

> តើ លេខសម្ងាត់សម្រាប់បញ្ជាក់ គឺជាអ្វីទៅ?
> លេខសម្ងាត់សម្រាប់បញ្ជាក់ ត្រូវប្រើដោយ ឪពុកម្តាយ ឬ អាណាព្យាបាល ដើម្បីចុះឈ្មោះ។ គេត្រូវការ លេខសម្ងាត់សម្រាប់បញ្ជាក់ តែម្តងប៉ុណ្ណោះ ហើយវានឹងអស់សុពលភាពនៅថ្ងៃទីមួយ ជារៀងរាល់ខែ។ លោកអ្នកអាចសុំ លេខសម្ងាត់សម្រាប់បញ្ជាក់ ពីសាលារបស់កូនលោកអ្នក ឬ លោកអ្នកអាចចុះឈ្មោះតាមអ៊ីនធ័រណិតនេះតែម្តង។

## ២) បើសិនជាលោកអ្នកមាន លេខសម្ងាត់សម្រាប់បញ្ជាក់៖

- ចុចលើ Yes នាំខ្ញុំទៅចុះឈ្មោះគណនី។
- បញ្ចូលនាមត្រកូលរបស់លោកអ្នក និង លេខសម្ងាត់សម្រាប់បញ្ជាក់។ ចុច Next (បន្ទាប់)។
- បញ្ចូល អ៊ីមែល របស់លោកអ្នក។
- បញ្ជាក់គណនីអ៊ីមែលរបស់លោកអ្នកដោយចុចលើបណ្តាញតភ្ជាប់ដែលគេបានផ្តល់ជូននៅក្នុងសារអ៊ីមែល។
- ចុចលើបណ្តាញតភ្ជាប់វិបសៃនៅក្នុងអ៊ីមែលដើម្បីបញ្ចប់ការចុះឈ្មោះរបស់លោកអ្នក។
- បន្ទាប់ពីលោកអ្នកបានបញ្ជាក់ពីការចុះឈ្មោះរួចហើយ លោកអ្នកនឹងរៀបចំ «ការរៀបចំសុវត្ថិភាព» របស់លោកអ្នក។ ជ្រើសរើសពាក្យសម្ងាត់ និងផ្តល់ចម្លើយទៅនឹងសំណួរសុវត្ថិភាពចំនួនបី។
- ចូលទៅគណនីថ្មីរបស់លោកអ្នក ដោយប្រើ អ៊ីមែល និង ពាក្យសម្ងាត់ ថ្មីរបស់លោកអ្នក។

## ៣) បើសិនជាលោកអ្នកគ្មានលេខសម្ងាត់សម្រាប់បញ្ជាក់ ទេ៖

- ចុចលើ No ខ្ញុំចង់ស្វែងរកលេខសម្ងាត់សម្រាប់បញ្ជាក់របស់ខ្ញុំ។
- បញ្ចូលពត៌មានផ្ទាល់ខ្លួនរបស់កូនលោកអ្នក (បើសិនជាលោកអ្នកមានកូនច្រើនជាងម្នាក់ លោកអ្នកគ្រាន់តែបញ្ចូលព័ត៌មានរបស់កូនតែម្នាក់ប៉ុណ្ណោះ។) ជ្រើសរើស ឈ្មោះ និង លេខទូរស័ព្ទ បច្ចុប្បន្នរបស់លោកអ្នកពីឯកសាររបស់កូនលោកអ្នក ដើម្បីស្នើសុំលេខសម្ងាត់សម្រាប់បញ្ជាក់។ គេអាចផ្ញើ លេខសម្ងាត់សម្រាប់បញ្ជាក់ តាម សារសម្លេង ឬ សារតាមទូរស័ព្ទដៃ។
- ឥឡូវនេះលោកអ្នកមានលេខសម្ងាត់សម្រាប់បញ្ជាក់របស់លោកអ្នកហើយ សូមចុចបណ្តាញតភ្ជាប់ដើម្បីត្រឡប់ទៅការចុះឈ្មោះគណនី ហើយចាប់ផ្តើមដំណើរការនេះ។

> **យើងខ្ញុំនៅទីនេះដើម្បីជួយ!**
>
> ទូរស័ព្ទមកយើងខ្ញុំ!
> ២១៥-៤០០-៤០០០
>
> ផ្ញើអ៊ីមែលមកយើងខ្ញុំ
> ask@philasd.org
>
> មើលព័ត៌មានរបស់យើងខ្ញុំ!
> philasd.org/pfportal

THE SCHOOL DISTRICT OF PHILADELPHIA